

# ការកំណត់ពេលវេលា ABAWD សម្រាប់ CalFresh

ចាប់ពីថ្ងៃទី **1 ខែមិថុនា ឆ្នាំ 2026 តទៅ** នាយកដ្ឋានសេវាសង្គមរដ្ឋកាលីហ្វ័រញ៉ានឹងចាប់ផ្តើមអនុវត្តការកំណត់ពេលវេលាសម្រាប់អ្នកទទួល CalFresh ដែលជាមនុស្សពេញវ័យមានកាយសម្បទារឹងមាំដោយគ្មានអ្នកនៅក្នុងបន្ទុក(ABAWD)។ខាងក្រោមនេះនិងពន្យល់អំពីច្បាប់ថ្មីនិងវិធីដែលអ្នកអាចរក្សាអត្ថប្រយោជន៍ផ្នែកអាហារដែលចាំបាច់របស់អ្នកបាន។

## តើនរណាខ្លះដែលត្រូវបានចាត់ទុកថាជា ABAWD?

អ្នកត្រូវបានចាត់ទុកថាជា ABAWD ប្រសិនបើអ្នកមានអាយុចន្លោះពី **18 ទៅ 64**ឆ្នាំ អាចធ្វើការបាន ហើយមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែងពីការកំណត់ពេលវេលារបស់ ABAWD ។

## តើការកំណត់ពេលវេលា ABAWD ជាអ្វី?

ABAWD អាចទទួលបានអត្ថប្រយោជន៍ CalFresh **បានតែ 3 ខែពេញប៉ុណ្ណោះក្នុងរយៈពេល 36 ខែ** លើកលែងតែពួកគេបំពេញតាមតម្រូវការការងារ ឬមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែង។

## តើធ្វើដូចម្តេចដើម្បីរក្សាអត្ថប្រយោជន៍របស់អ្នក?

ដើម្បីបន្តទទួលបាន CalFresh បន្ទាប់ពីរយៈពេល 3 ខែ អ្នកត្រូវតែបំពេញតាម**តម្រូវការការងារ** ឬមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែង។

## តើខ្ញុំត្រូវធ្វើអ្វីនៅថ្ងៃនេះ?

សម្រាប់ព័ត៌មានបន្ថែមអំពីការកំណត់ពេលវេលា ABAWD ឬការ**បំពេញទម្រង់បែបបទត្រួតពិនិត្យលើការលើកលែង ABAWD** សូមប្រើ កូដ **QR** ដើម្បីចូលទៅកាន់គេហទំព័រ ABAWD។ អ្នកក៏អាចចូលទៅកាន់ **socialservices.alamedacounty.gov**.

## តម្រូវការការងារ៖

**អ្នកត្រូវតែបំពេញតាមលក្ខខណ្ឌមួយឬច្រើនក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖**

- ធ្វើការយ៉ាងហោច 20 **ម៉ោងក្នុងមួយសប្តាហ៍** (ឬ 80 ម៉ោងក្នុងមួយខែ)
- តម្រូវឱ្យធ្វើការគ្រប់ 20 ម៉ោងក្នុងមួយសប្តាហ៍ (ឬ 80 ម៉ោងក្នុងមួយខែ) **ដោយបូកបញ្ចូល**ម៉ោងនៅកន្លែងការងារ និងម៉ោងនៃសកម្មភាពការងារដែលមានការអនុញ្ញាត។
- រកចំណូលឱ្យបានយ៉ាងហោច **$217.50 ក្នុងមួយសប្តាហ៍**
- **ចូលរួមសកម្មភាពការងារដែលមានការអនុញ្ញាត** ដូចជាកម្មវិធីការងារ CalFresh និងបណ្តុះបណ្តាលរបស់កម្មវិធី WIOA, គម្រោងសេវាកម្មសហគមន៍ឬការងារស្ម័គ្រចិត្ត

### ការលើកលែង៖

**អ្នកអាចទទួលបានការលើកលែង ប្រសិនបើអ្នក៖**

- ជាសិស្ស
- មានផ្ទៃពោះ
- មិនអាចធ្វើការបានដោយសារស្ថានភាពសុខភាពរាងកាយ ឬផ្លូវចិត្ត
- ត្រូវបានលើកលែងពីវិច្ឆាប់ការងាររបស់ CalFresh
- កំពុងរស់នៅជាមួយកុមារអាយុក្រោម 14 ឆ្នាំ
- ស្ថិតក្រោមកម្មវិធីណាមួយរបស់ការិយាល័យតាំងទីលំនៅថ្មីសម្រាប់ជនភៀសខ្លួន (ORR)
- ជនជាតិដើមអាមេរិក ជនជាតិដើមអាមេរិកក្នុងទីក្រុង ឬជនជាតិដើមអាមេរិកនៅរដ្ឋកាលីហ្វ័រញ៉ា

## សម្រាប់ព័ត៌មានបន្ថែម៖

ឬហៅទូរសព្ទមកយើង៖
**510-263-2420**

Alameda County
Social Services Agency
A safety net. A way forward.